01381634

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 26 / 01 / 2017
ម៉ោង (Time/Heure): 14:45
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

E319/67

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

**សាធារណៈ / Public**

## អង្គជំនុំជម្រះសាលាដំបូង

ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១៧

**ជូនចំពោះ៖** ភាគីទាំងអស់នៃសំណុំរឿង ០០២

**ពី៖** ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង

**ចម្លងជូន៖** លោក/លោកស្រីចៅក្រម និង មន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង

**កម្មវត្ថុ៖** ការទទួលយកកំណត់ហេតុនៃការស្តាប់ចម្លើយដែលបានដាក់បង្ហាញនាពេលថ្មីៗពីក្នុងសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលបានមកផ្តល់សក្ខីកម្មនៅក្នុងអំឡុងពេលកិច្ចដំណើរការនៃនីតិវិធីនៅក្នុងសំណុំរឿង ០០២

១. សហព្រះរាជអាជ្ញាអន្តរជាតិបានដាក់សំណើចំនួនពីរ សុំឱ្យអង្គជំនុំជម្រះទទួលយកធ្វើជាភ័ស្តុតាងនូវកំណត់ហេតុនៃការស្តាប់ចម្លើយ ដែលបានដាក់បង្ហាញពីក្នុងសំណុំរឿង ០០៣ និង ០០៤ របស់សាក្សីដែលបានមកផ្តល់សក្ខីកម្មនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ (ឯកសារ E319/63 កថាខណ្ឌ ៦(ខ), ឯកសារ E319/66 កថាខណ្ឌ ៥(ខ))។ ភាគីដទៃទៀតមិនដាក់ចម្លើយតបទៅនឹងសំណើទាំងនេះឡើយ។

២. អង្គជំនុំជម្រះសាលាដំបូងរម្លឹកអំពីការអនុវត្តរបស់ខ្លួនក្នុងការទទួលយកធ្វើជាភ័ស្តុតាងនូវរាល់ចម្លើយពីមុនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ឬ សាក្សី ដែលបានមកផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ អនុលោមតាមវិធាន ៨៧(៣) និង ៨៧(៤) នៃវិធានផ្ទៃក្នុង។ ដើម្បីជា

ប្រយោជន៍នៃការស្វែងរកការពិត អង្គជំនុំជម្រះ និងភាគីអាចចូលពិនិត្យមើលរាល់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និងសាក្សីដែលនឹងត្រូវមកផ្ដល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០២ (ឯកសារ E421/4 កថាខណ្ឌ ១២)។

៣. ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចទទួលយកធ្វើជាឯកសារភ័ស្ដុតាងនូវកំណត់ហេតុនៃការស្ដាប់ចម្លើយនានា ដែលស្នើសុំដោយសហព្រះរាជអាជ្ញាអន្តរជាតិ ហើយដាក់លេខយោងជាឯកសារ៖ E3/10775, E3/10776, E3/10777, E3/10778, E3/10778.1, E3/10778.2, E3/10778.3, E3/10779, E3/10784, E3/10784/1 និង E3/10780, E3/10781, E3/10781.1, E3/1782, E3/10782.1, E3/10783 (ឯកសារ E319/66) (សូមមើល អង្គជំនុំជម្រះបានដាក់លេខយោងសម្រាប់ឯកសារទាំងនេះ ទៅតាមលេខឯកសារដែលបានយោងនៅក្នុងឯកសារ E319/63.3, E319/63.4 និង E319/64.7)។

៤. អង្គជំនុំជម្រះក៏ពិចារណាផងដែរ តាមគំនិតផ្ដួចផ្ដើមរបស់ខ្លួន ថាតើអង្គជំនុំជម្រះគួរទទួលយកកំណត់ហេតុនៃការស្ដាប់ចម្លើយសាក្សី ដែលបានមកផ្ដល់សក្ខីកម្មនៅក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ដែលជាផ្នែកមួយនៃសំណើរបស់សហព្រះរាជអាជ្ញាអន្តរ-ជាតិឱ្យដាក់បង្ហាញឯកសារទាំងនោះតាមរយៈអ៊ីម៉ែល ចុះនៅថ្ងៃទី ០៧ ខែ ធ្នូ ឆ្នាំ ២០១៦ (ឯកសារ E319/67.1 ភ្ជាប់ជាមួយនឹងអនុស្សរណៈនេះ) ដែរ ឬ ទេ។ ទោះបីជាឯកសារមួយចំនួនដែលស្នើសុំឱ្យដាក់បង្ហាញនោះមាននៅក្នុងសំណុំរឿង និង/ឬ ត្រូវបានទទួលយករួចមកហើយក៏ដោយ តែកំណត់ហេតុនៃការស្ដាប់ចម្លើយដែលត្រូវបានដាក់បង្ហាញនាពេលថ្មីៗនេះមានព័ត៌មានបន្ថែមក្នុងទម្រង់ជាចំណារដែលអាចបន្ថែមលើខ្លឹមសារសំខាន់ ឬ សេចក្ដីលម្អិតដែលមិនមានពីមុនមកនោះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសម្រេចទទួលយកធ្វើជាឯកសារភ័ស្ដុតាងនូវ៖ ឯកសារ E3/10573.1, E3/9698.1, E3/9698.2, E3/10574.1, E3/10574.2 និង E3/10574.3 (សូមមើល ឯកសារ E319/67.4)។

៥. អនុស្សរណៈនេះ គឺជាការឆ្លើយតបផ្លូវការរបស់អង្គជំនុំជម្រះទៅនឹងសំណើ E319/63 និង E319/66។